PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# កម្រងសំណួរ-ចម្លើយសំខាន់ៗសម្រាប់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ

## លក្ខណៈសម្បត្តិផលិតផល៖

1. **តើអ្វីទៅជា PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ?**

   PRUថែទាំ ជាផលិតផលធានារ៉ាប់រងអាយុជីវិតដែលមានលក្ខណៈជាការធានារ៉ាប់រងមានកាលកំណត់សម្រាប់ផ្តល់ជូនអត្ថប្រយោជន៍ធានារ៉ាប់រងក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដោយម្ចាស់បណ្ណសន្យារ៉ាប់រងនឹងមិនទទួលបានការប្រាក់ភាគលាភ និង ផលចំណេញផ្សេងៗ ដែលបានមកពីការវិនិយោគទៅលើបុព្វលាភធានារ៉ាប់រងដែលបានបង់នោះឡើយ (Non-participating) និងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ ផលិតផលធានារ៉ាប់រងបន្ថែមដែលអាចទិញភ្ជាប់ទៅនឹងផលិតផលនេះគឺផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ ដែលផ្តល់ការការពារផ្នែកហិរញ្ញវត្ថុលើលក្ខខណ្ឌវេជ្ជសាស្ត្រដែលបានផ្តល់ជូនរួមមាន ករណីជំងឺធ្ងន់ធ្ងរ ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ) ផលវិបាកនៃការមានគភ៌ ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក និងផលវិបាកនៃជំងឺទឹកនោមផ្អែម។

2. **តើអតិថិជនណាខ្លះដែលអាចជាវផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ?**

   អតិថិជនដែលអាចជាវផលិតផលនេះរួមមាន៖
   - ក. និតិបុគ្គលដែលបានចុះបញ្ជី និងប្រតិបត្តិការក្នុងប្រទេសកម្ពុជា ឬ
   - ខ. រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ កំពុងរស់នៅក្នុងប្រទេសកម្ពុជាយ៉ាងតិចណាស់ 6 ខែ ដោយមានអាសយដ្ឋានពិតប្រាកដនៅប្រទេសកម្ពុជា និងមានអាយុចាប់ពី 18 ទៅ 60 ឆ្នាំដែលប្រើប្រាស់ Smartphone។

3. **តើអ្វីទៅជារយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង សម្រាប់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ?**

   រយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង គឺជារយៈពេលដែលការធានារ៉ាប់រងអាយុជីវិតត្រូវបានផ្តល់ជូន។ រយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងសម្រាប់ផលិតផលនេះគឺ 5 (ប្រាំ) ឆ្នាំ។

4. **តើអត្ថប្រយោជន៍របស់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ មានអ្វីខ្លះ?**

   ប្រសិនបើអត្ថប្រយោជន៍ណាមួយខាងក្រោមនេះត្រូវបានជ្រើសរើស នោះវានឹងត្រូវបានទូទាត់ជូនដូចខាងក្រោម៖

| ប្រភេទនៃអត្ថប្រយោជន៍ | អត្ថប្រយោជន៍ទទួលបាន |
|---|---|
| អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ | 100% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងនឹងត្រូវបានទូទាត់ជូនក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ |

| | |
|---|---|
| ជំងឺធ្ងន់ធ្ងរ<br>(Critical Illness) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 500% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរណាមួយដូចដែលបានកំណត់ចំនួន 5 ករណី។ បុព្វលាភធានារ៉ាប់រងនាពេលអនាគតរបស់អត្ថប្រយោជន៍ផ្សេងទៀតនឹងត្រូវបានលើកលែង ក្នុងករណីមានការទាមទារសំណងសម្រាប់អត្ថប្រយោជន៍នេះបានជោគជ័យ។ |
| ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ<br>(Juvenile Medical Conditions) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 500% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារណាមួយដូចដែលបានកំណត់ចំនួន 10ករណី។ បុព្វលាភធានារ៉ាប់រងនាពេលអនាគតរបស់អត្ថប្រយោជន៍ផ្សេងទៀតនឹងត្រូវបានលើកលែង ក្នុងករណីមានការទាមទារសំណងសម្រាប់អត្ថប្រយោជន៍នេះបានជោគជ័យ។ |
| អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)<br>(Extra Gender Specific Cancer) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 100% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺមហារីកណាមួយដូចដែលបានរាយខាងក្រោម៖<br>- **ចំពោះស្ត្រី:** មហារីកសុដន់ មហារីកមាត់ស្បូន និង មហារីកស្បូន<br>- **ចំពោះបុរស:** មហារីកក្រពេញប្រូស្តាត មហារីកពងស្វាស និង មហារីកលិង្គ<br>អត្ថប្រយោជន៍នេះជាអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមលើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ។ |
| ផលវិបាកនៃការមានគភ៌<br>(Pregnancy Complications) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 50% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានស្ថានភាពណាមួយដូចដែលបានកំណត់ចំពោះអត្ថប្រយោជន៍ផលវិបាកនៃការមានគភ៌។ |
| ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក<br>(Reconstructive Surgery or Skin Grafting) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 10% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងក្នុងករណីការវះកាត់ស្តារឡើងវិញដោយសារគ្រោះថ្នាក់ ឬការផ្សាំស្បែកដោយសារការរលាកធ្ងន់ធ្ងរ (សម្រាប់តែក្រុមមុខរបរ 1 និង 2 តែប៉ុណ្ណោះ)។<br><br>អត្ថប្រយោជន៍នេះត្រូវបានផ្តល់ជូនតែម្តងគត់ ក្នុងមួយករណីគ្រោះថ្នាក់ចៃដន្យ ឬករណីរលាកធ្ងន់ធ្ងរ និងតែម្តងគត់ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។ អត្ថប្រយោជន៍នេះអាចធ្វើការទាមទារសំណងរហូតដល់ 3 ដង ដែលការទាមទារសំណងនីមួយៗត្រូវស្ថិតក្នុងឆ្នាំបណ្ណសន្យារ៉ាប់រងខុសគ្នា និង កើតឡើងដោយសារករណីគ្រោះថ្នាក់ចៃដន្យឬករណីរលាកធ្ងន់ធ្ងរផ្សេងគ្នា។ អត្ថប្រយោជន៍នេះនឹងត្រូវបានបញ្ចប់ក្នុងករណីដែលមានការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ឬ ការទាមទារសំណងលើកទី 3 សម្រាប់អត្ថប្រយោជន៍នេះត្រូវបានផ្តលជូន។ |
| ផលវិបាកនៃជំងឺទឹកនោមផ្អែម<br>(Diabetic Complications) | អត្ថប្រយោជន៍បន្ថែមទទួលបានស្មើនឹង 25% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងត្រូវឆ្លងកាត់ការព្យាបាល និងត្រូវបានធ្វើរោគវិនិច្ឆ័យថាមានស្ថានភាពណាមួយដូចដែលបានកំណត់ចំពោះអត្ថប្រយោជន៍ផលវិបាកនៃជំងឺទឹកនោមផ្អែម។ |

សូមទៅកាន់បណ្ណសន្យារ៉ាប់រងសម្រាប់លក្ខខណ្ឌ/ករណីដែលបានធានារ៉ាប់រងចំពោះអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ ជំងឺកើតឡើងលើកុមារ និងផលវិបាកនៃការមានគភ៌។

សម្គាល់៖ ទឹកប្រាក់ត្រូវបានធានារ៉ាប់រង សំដៅដល់ចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងត្រូវការសម្រាប់ការធានារ៉ាប់រងនៅក្នុងផលិតផលធានារ៉ាប់រងដែលនឹងទទួលបាននៅពេលមានហេតុការណ៍ត្រូវបានធានាណាមួយកើតឡើង ដោយយោងតាមខ និងលក្ខខណ្ឌដូចមានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង។

## 5. តើករណីមិនធានារបស់ផលិតផល PRUថែទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ មានអ្វីខ្លះ?

### 5.1. ករណីមិនធានារបស់ផលិតផលធានារ៉ាប់រង PRUថែទាំ

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានកើតឡើងដូចលក្ខខណ្ឌណាមួយខាងក្រោម៖

- ការធ្វើអត្តឃាត ឬ ការប៉ុនប៉ងធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
- ការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តដោយអ្នកទទួលផលម្នាក់ ឬ ច្រើននាក់ នោះមានតែអ្នកទទួលផលដែលមិនពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះដែលនៅមានសិទ្ធិក្នុងការទទួលអត្ថប្រយោជន៍។
- ការប្រើគ្រឿងញៀន ឬ ថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬ បើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- ស្ថានភាព ឬជំងឺមានពីមុនស្រាប់ ដូចដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងរបស់ផលិតផលនេះ។

### 5.2. ករណីមិនធានារបស់ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងត្រូវបានកើតឡើងដោយផ្ទាល់ ឬ ប្រយោលចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

- ស្ថានភាព ឬជំងឺមានពីមុនស្រាប់ ដូចដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងរបស់ផលិតផលនេះ។
- ជំងឺឬស្ថានភាពណាមួយដែលមានវត្តមាន ឬត្រូវបានធ្វើរោគវិនិច្ឆ័យក្នុងរយៈពេលរង់ចាំ។
- ការធ្វើអត្តឃាត ការប៉ុនប៉ងធ្វើអត្តឃាត ឬ ការធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
- ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ ការបង្កឲ្យមានការវាយប្រហារ ឬបទ ល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល។
- ស្ថិតក្រោមឥទ្ធិពលនៃការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង។
- ការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺ ឬស្ថានភាពណាមួយ ដោយសារភាពមិនប្រក្រតីពីកំណើតមិនថាដោយផ្ទាល់ ឬដោយប្រយោលក៏ដោយ។
- អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេលរយៈពេលរស់រានមានជីវិតដូចដែលបានចែងក្នុងចំណុចទី ៧។

ប្រសិនបើអត្ថប្រយោជន៍លើ**ការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក** ត្រូវបានជ្រើសរើស នោះករណីមិនធានាខាងក្រោមនេះក៏នឹងត្រូវបានអនុវត្តបន្ថែមពីលើករណីមិនធានាខាងលើផងដែរ។ ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថ

ប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងត្រូវបានកើតឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

- ការព្យាបាលសម្រាប់ជំងឺ ឬរបួសបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រងចូលរួមនៅក្នុងសកម្មភាពដែលងាយមានគ្រោះថ្នាក់ ឬសកម្មភាពកីឡាសម្រាប់ការកំសាន្តឬអាជីព ឬ សកម្មភាពឬកីឡាផ្សេងៗដែលអាចរកប្រាក់ចំណូលពីសកម្មភាពទាំងនោះ។
- ការងើបបះបោរប្រឆាំងរដ្ឋាភិបាល កូដកម្ម ភេរវកម្ម ការរំលោភឬការប៉ុនប៉ងរំលោភច្បាប់ ការទប់ទល់ប្រឆាំងទៅនឹងការចាប់ខ្លួនឬការដាក់ពន្ធនាគារណាមួយ។
- ផលវិបាកដែលកើតឡើងដោយផ្ទាល់ឬដោយប្រយោលពី ការធ្លាក់នុយក្លេអ៊ែរ វិទ្យុសកម្ម សមាសភាពនុយក្លេអ៊ែរ សម្ភារៈឬកាកសំណល់នុយក្លេអ៊ែរ និង ហានិភ័យពាក់ព័ន្ធនឹងសង្គ្រាមផ្សេងៗទៀត។

### 6. តើអ្វីទៅជារយៈពេលរង់ចាំ?

រយៈពេលរង់ចាំ សំដៅដល់កំឡុងពេលជាក់លាក់ក្រោយកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ឬ កាលបរិច្ឆេទនៃការកែប្រែកិច្ចសន្យាធានារ៉ាប់រង (សំដៅទៅកាលបរិច្ឆេទបន្តសុពលភាពបណ្ណសន្យារ៉ាប់រង) ដោយសារការផ្លាស់ប្តូរអត្ថប្រយោជន៍ធានារ៉ាប់រង (សម្រាប់ការបន្ថែមទំហំទឹកប្រាក់ត្រូវបានធានារ៉ាប់រង) ដោយយកកាលបរិច្ឆេទចុងក្រោយគេ ដែលក្នុងកំឡុងពេលនេះការទាមទារសំណង ឬអត្ថប្រយោជន៍ធានារ៉ាប់រងមិនត្រូវបានផ្តល់ជូនទេ។

រយៈពេលរង់ចាំមានដូចខាងក្រោម៖

ក. ជំងឺធ្ងន់ធ្ងរ ជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ) ផលវិបាកនៃជំងឺទឹកនោមផ្អែម៖ 90 (កៅសិប) ថ្ងៃ

ខ. ផលវិបាកនៃការមានគភ៌៖ 300 (បីរយ) ថ្ងៃ។

### 7. តើអ្វីទៅជារយៈពេលរស់រានមានជីវិត?

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើការទាមទារសំណងត្រូវបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោលចំពោះអ្នកត្រូវបានធានារ៉ាប់រងដូចខាងក្រោម៖

ក. អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូង ដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានជំងឺធ្ងន់ធ្ងរ លើកលែងតែជំងឺមហារីកដំណាក់កាលធ្ងន់ធ្ងរ។

ខ. អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងអំឡុងពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូង ដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ។

គ. អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពក្នុងរយៈពេល 14 (ដប់បួន) ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដំបូង ដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានផលវិបាកនៃជំងឺទឹកនោមផ្អែម។

### 8. តើកាលបរិច្ឆេទចាប់ផ្តើមមានសុពលភាពនៃការធានាចាប់ផ្តើមនៅពេលណាបន្ទាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រងរួច? តើវាមានដំណើរការយ៉ាងដូចម្តេច?

កាលបរិច្ឆេទចាប់ផ្តើមមានសុពលភាពនៃការធានានឹងចាប់ផ្តើមបន្ទាប់ពីរយៈពេលរង់ចាំដូចដែលបានរៀបរាប់ក្នុងចំណុចទី 6 ខាងលើ។

9. **តើមានការវាយតម្លៃផ្នែកសុខភាព ឬ មានការពិនិត្យសុខភាព សម្រាប់ការធានារ៉ាប់រងផលិតផល PRUថៃទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ ?**

មានដំណើរការចេញបណ្ណសាមញ្ញ សម្រាប់អតិថិជននៅពេលធ្វើការធានារ៉ាប់រងបណ្ណសន្យារ៉ាប់រង។ អតិថិជនគ្រាន់តែត្រូវធ្វើការបំពេញលើសន្ទស្សន៍ម៉ាសរាងកាយ (កំពស់ និងទំងន់) និង ធ្វើសេចក្តីប្រកាសលើសុខភាពឬឆ្លើយសំណួរលើសុខភាព ចំនួន 2 (ពីរ) តែប៉ុណ្ណោះ។ ក្នុងករណីអត្ថប្រយោជន៍ផលវិបាកនៃការមានគភ៌ត្រូវបានជ្រើសរើស នោះអតិថិជននឹងតម្រូវឲ្យធ្វើសេចក្តីប្រកាសលើសុខភាពឬឆ្លើយសំណួរលើសុខភាពចំនួន 1 (មួយ) ទៀត។

បណ្ណសន្យារ៉ាប់រងនឹងត្រូវចេញភ្លាមៗដោយក្រុមហ៊ុន ក្រោយពីអតិថិជនបានបំពេញព័ត៌មានដែលចាំបាច់ និងធ្វើសេចក្តីប្រកាសរួចរាល់។

10. **តើមានរយៈពេលអនុគ្រោះត្រូវបានអនុញ្ញាតសម្រាប់ផលិតផលធានារ៉ាប់រងនេះ ក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងដែរឬទេ?**

មានរយៈពេលអនុគ្រោះ 30 (សាមសិប) ថ្ងៃ សម្រាប់បណ្ណសន្យារ៉ាប់រងនេះ។ ប្រសិនបើអ្នកមិនបានបង់បុព្វលាភធានារ៉ាប់រងដែលនៅពុំទាន់បានបង់ នៅថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះនេះទេ នោះបណ្ណសន្យារ៉ាប់រងនឹងក្លាយទៅជាអស់សុពលភាពបណ្តោះអាសន្ន ដោយកាលបរិច្ឆេទអស់សុពលភាពជាបណ្តោះអាសន្ននេះ គឺរាប់ចាប់ពីកាលបរិច្ឆេទដល់ការកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងនៃបុព្វលាភធានារ៉ាប់រងដែលផុតកំណត់ហើយដែលពុំទាន់បានបង់នោះ។

11. **តើបណ្ណសន្យារ៉ាប់រងរបស់ខ្ញុំនឹងក្លាយជា អស់សុពលភាពជាបណ្តោះអាសន្នដែរឬទេ ប្រសិនបើខ្ញុំពុំបានបង់បុព្វលាភធានារ៉ាប់រងតាមការសន្យា?**

បណ្ណសន្យារ៉ាប់រងនឹងត្រូវអស់សុពលភាពជាបណ្តោះអាសន្ន ក្នុងករណីដែលបុព្វលាភធានារ៉ាប់រងទៀងទាត់ដែលដល់កាលកំណត់មិនត្រូវបានទូទាត់បន្ទាប់ពីផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយអត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងមិនត្រូវបានផ្តល់ជូនទៀតទេ។

នៅពេលដែលបណ្ណសន្យារ៉ាប់រងនេះត្រូវបានអស់សុពលភាពជាបណ្តោះអាសន្ន ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបានអនុញ្ញាតិឲ្យធ្វើការស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ក្នុងរយៈពេល 6 (ប្រាំមួយ) ខែ ដោយគិតចាប់ពីថ្ងៃបណ្ណសន្យារ៉ាប់រងនេះអស់សុពលភាពជាបណ្តោះអាសន្ន ដោយធ្វើការទូទាត់បុព្វលាភធានារ៉ាប់រងទាំងអស់ដែលពុំទាន់បានបង់រួមជាមួយនឹងការប្រាក់ប្រសិនបើមាន និងអាស្រ័យទៅតាមច្បាប់និងបទបញ្ញត្តិដែលបានចែងស្តីពីការបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រងឡើងវិញ។

## <u>បុព្វលាភធានារ៉ាប់រង និង ការទូទាត់ផ្សេងៗ៖</u>

12. **តើផលិតផល PRUថៃទាំ និង ផលិតផលធានារ៉ាប់រងបន្ថែម PRUការពារជំងឺធ្ងន់ធ្ងរ មានភាពញឹកញាប់នៃការបង់បុព្វលាភធានារ៉ាប់រងប៉ុន្មានជម្រើស? តើបុព្វលាភធានារ៉ាប់រងមានការធានាដែរឬទេ?**

ការបង់បុព្វលាភធានារ៉ាប់រងអាស្រ័យទៅលើភាពញឹកញាប់នៃការបង់បុព្វលាភធានារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងនឹងត្រូវបានគណនាផ្អែកទៅលើ អាយុ ភេទ ភាពញឹកញាប់នៃការបង់បុព្វលាភធានារ៉ាប់រង ទឹកប្រាក់ត្រូវបានធានារ៉ាប់រង និងអត្ថប្រយោជន៍ដែលអតិថិជនបានជ្រើសរើស។

បុព្វលាភធានារ៉ាប់រងនឹងត្រូវបានធានាក្នុងរយៈពេល 5 (ប្រាំ) ឆ្នាំនៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងនឹងមានការប្រែប្រួលរាល់ពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ដែលបុព្វលាភធានារ៉ាប់រងថ្មីនោះនឹង

ផ្អែកទៅលើ អាយុនៅពេលធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ទឹកប្រាក់ត្រូវបានធានារ៉ាប់រង និងការផ្លាស់ប្តូរនៃអត្ថប្រយោជន៍ធានារ៉ាប់រងដែលអតិថិជនបានជ្រើសរើស។

ម្ចាស់បណ្ណសន្យាធានារ៉ាប់រង និង/ឬក្រុមហ៊ុនរក្សាសិទ្ធមិនបន្តសុពលភាពបណ្ណសន្យារ៉ាប់រងសម្រាប់ផលិតផល។

## សេវាកម្មផ្សេងៗលើបណ្ណសន្យារ៉ាប់រង៖

**13. បន្ទាប់ពីខ្ញុំបានជាវបណ្ណសន្យារ៉ាប់រងនេះ តើខ្ញុំអាចទាក់ទងទៅកាន់អ្នកណា ចំពោះសេវាកម្មលើបណ្ណសន្យារ៉ាប់រង និងប្រសិនបើខ្ញុំមានចម្ងល់ ឬ សំណួរផ្សេងៗលើបណ្ណសន្យារ៉ាប់រង?**

សម្រាប់ជំនួយលើសេវាកម្ម និង សំណួរផ្សេងៗ លោកអ្នកអាចទាក់ទងទៅកាន់ផ្នែកសេវាកម្មអតិថិជនដូចខាងក្រោម៖

- លេខទូរស័ព្ទទំនាក់ទំនង ៖ 023 964 222 ឬ 1800 21 22 23 (ឥតគិតថ្លៃ)
- អ៊ីម៉ែល ៖ info@prudential.com.kh
- គេហទំព័រហ្វេសប៊ុក ៖ Prudential Cambodia
- គេហទំព័រ ៖ www.prudential.com.kh/

**14. តើខ្ញុំអាចទទួលបានឯកសារបណ្ណសន្យារ៉ាប់រងបានដោយរបៀបណា បន្ទាប់ពីជាវបណ្ណសន្យារ៉ាប់រងរួច?**

នៅពេលដែលបណ្ណសន្យារ៉ាប់រងរបស់លោកអ្នកត្រូវបានចេញដោយក្រុមហ៊ុន លោកអ្នកនឹងទទួលការបញ្ជាក់ពីក្រុមហ៊ុនភ្លាមៗ ហើយលោកអ្នកនឹងអាចមើលបណ្ណសន្យារ៉ាប់រងរបស់អ្នកនៅក្នុងផ្នែក "សេវាកម្មព្រូដិនសល" លើកម្មវិធីទូរស័ព្ទដៃរបស់ក្រុមហ៊ុនព្រូដិនសល ឈ្មោះថា Pulse។

**15. តើខ្ញុំអាចផ្លាស់ប្តូរព័ត៌មានលម្អិតទំនាក់ទំនងរបស់ខ្ញុំដោយរបៀបណា?**

លោកអ្នកអាចផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាព អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងរបស់អ្នកនៅក្នុងផ្នែក "សេវាកម្មព្រូដិនសល" លើកម្មវិធីទូរស័ព្ទដៃរបស់ក្រុមហ៊ុនព្រូដិនសល ឈ្មោះថា Pulse។

**16. តើខ្ញុំអាចផ្លាស់ប្តូររយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងបានដែរឬទេ បន្ទាប់ពីជាវបណ្ណសន្យារ៉ាប់រងរួច ?**

លោកអ្នកមិនអាចផ្លាស់ប្តូររយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាពបាននោះទេ។

**17. តើខ្ញុំអាចផ្លាស់ប្តូរអ្នកទទួលផលបានដែរឬទេ បន្ទាប់ពីជាវបណ្ណសន្យារ៉ាប់រងរួច?**

អ្នកទទួលផលដោយស្វ័យប្រវត្តិត្រូវបានកំណត់ដូចដែលមានចែងនៅក្នុងឯកសារបណ្ណសន្យារ៉ាប់រងនៃផលិតផលនេះ ហើយលោកអ្នកអាចធ្វើការផ្លាស់ប្តូរអ្នកទទួលផលភ្លាមៗ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងបានចេញដោយក្រុមហ៊ុន។

## ការទាមទារសំណង៖

**18. តើខ្ញុំត្រូវដាក់សំណើទាមទារសំណងក្នុងរយៈពេលប៉ុន្មាន?**

ការដាក់សំណើទាមទារសំណងដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលត្រូវបានធានា តម្រូវឲ្យដាក់ស្នើមកកាន់ ក្រុមហ៊ុនក្នុងអំឡុងពេល 30 ថ្ងៃបន្ទាប់ពីថ្ងៃដែលព្រឹត្តិការណ៍នោះបានកើតឡើង។

## 19. តើខ្ញុំត្រូវដាក់សំណើស្នើទាមទារសំណងយ៉ាងដូចម្តេច?

លោកអ្នកអាចដាក់សំណើទាមទារសំណងតាមរយៈ ៖

ក. ដាក់សំណើតាមរយៈកម្មវិធីទូរស័ព្ទដៃរបស់ក្រុមហ៊ុនព្រូដិនសលPulse ។

ខ. លោកអ្នកអាចដាក់សំណើរទាមទារសំណងតាមរយៈផ្នែកសេវាកម្មអតិថិជននៅក្រុមហ៊ុនព្រូដិនសល ដែលមានអាសយដ្ឋាននៅ៖ អគារវីត្រាស់ថាវើរ៍ ជាន់ផ្ទាល់ដី, #24 ផ្លូវលេខ 169 (មហាវិថីឆេកូស្លូវ៉ាគី) សង្កាត់វាលវង់ ខណ្ឌ 7 មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**<u>ទំនាក់ទំនងផ្នែកទាមទារសំណង</u>**

- អ៊ីម៉ែល៖ pcla.claims@prudential.com.kh
- លេខទូរស័ព្ទ៖ 095 964 222

## 20. តើឯកសារអ្វីខ្លះដែលតម្រូវចាំបាច់សម្រាប់ដាក់សំណើរទាមទារសំណង?

អ្នកត្រូវបានតម្រូវឱ្យសម្រាប់បំពេញព័ត៌មាន/ឯកសារខាងក្រោមសម្រាប់សំណើរការទាមទារសំណងសម្រាប់ផលិតផល **PRUថែទាំ** មានដូចជា៖

ក. ទម្រង់បែបបទទាមទារសំណង

ខ. សំបុត្រមរណភាព សំបុត្រមរណភាពនៅក្រៅប្រទេស លិខិតនៃការដឹកសពចូលមកក្នុងប្រទេសកំណើតវិញ ឬ លិខិតបូជាសព ប្រសិនបើហេតុការណ៍មរណភាពកើតឡើងនៅក្រៅប្រទេសកម្ពុជា ឬ លិខិតបញ្ជាក់ពីការពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និង

គ. ឯកសារដែលបញ្ជាក់ពីគ្រោះថ្នាក់ចៃដន្យនិងឯកសារវេជ្ជសាស្ត្រ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (សម្រាប់ករណីគ្រោះថ្នាក់ចៃដន្យ) ឬ ឯកសារវេជ្ជសាស្ត្រ (សម្រាប់ករណីមិនមែនគ្រោះថ្នាក់ចៃដន្យ) និង

ឃ. សម្រាប់ការទាមទារសំណងករណីមរណភាព ឯកសារបញ្ជាក់ទំនាក់ទំនង (លិខិតថតចម្លង សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅរបស់អ្នកត្រូវបានធានារ៉ាប់រង) និងលិខិតថតចម្លង លិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណអ្នកទាមទារសំណង និង

ង. លិខិតថតចម្លង គណនីធនាគារ របស់អ្នកទាមទារសំណង។

អ្នកត្រូវបានតម្រូវឱ្យសម្រាប់បំពេញព័ត៌មាន/ឯកសារខាងក្រោមសម្រាប់សំណើរការទាមទារសំណងគម្រោងអត្ថប្រយោជន៍បន្ថែម **PRUការពារជំងឺធ្ងន់ធ្ងរ** ដូចជា៖

ក. ទម្រង់បែបបទទាមទារសំណង

ខ. លិខិតចម្លងនៃការបញ្ជាក់ពីវេជ្ជបណ្ឌិត ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រចេញដោយគ្រូពេទ្យជំនាញទៅលើករណីត្រូវបានធានារ៉ាប់រង (ឯកសារបញ្ជាក់អាចជាអក្សរខ្មែរ ឬអង់គ្លេស)

គ. របាយការណ៍រោគសាស្ត្រ ឬរបាយការណ៍ច្រឹបសាច់ ឬរបាយការណ៍ជាលិកាសាស្ត្រ ក្នុងករណីបើការធ្វើតេស្តនេះត្រូវបានធ្វើឡើង។

## 21. តើខ្ញុំពិនិត្យមើលស្ថានភាពពាក្យស្នើសុំទាមទារសំណងរបស់ខ្ញុំ ឬ បញ្ជាក់ពីចង្ងល់បន្ថែមទាក់ទងនឹងសេចក្តីសម្រេចទាមទារសំណងយ៉ាងដូចម្តេច?

សម្រាប់ជំនួយលើសេវាកម្ម និង សំណួរផ្សេងៗ លោកអ្នកអាចទាក់ទងទៅកាន់៖

- លេខទាក់ទង ៖ 095 964 222
- អ៊ីម៉ែល ៖ pcla.claims@prudential.com.kh

## ការបញ្ចប់បណ្ណសន្យារ៉ាប់រង

**22. តើដំណើរការនៃការបញ្ចប់បណ្ណសន្យារ៉ាប់រង សម្រាប់ផលិតផលនេះ ប្រព្រឹត្តទៅយ៉ាងដូចម្តេច?**

បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅកាលដែលហេតុការណ៍ណាមួយខាងក្រោមកើតឡើង៖

ក. ករណីមរណភាព ឬ ករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង **ឬ**

ខ. ករណីដែលបានទូទាត់សំណងទៅតាមអត្ថប្រយោជន៍នៃបណ្ណសន្យារ៉ាប់រងជូនរួចរាល់ទៅតាមលក្ខខណ្ឌក្រោមបណ្ណសន្យារ៉ាប់រងនេះ **ឬ**

គ. បន្ទាប់ពីទទួលបានសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបោះបង់បណ្ណសន្យារ៉ាប់រង **ឬ**

ឃ. ដល់ថ្ងៃផុតកំណត់នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង **ឬ**

ង. អ្នកត្រូវបានធានារ៉ាប់រងបានដល់អាយុផុតសុពលភាពធានារ៉ាប់រង (អាយុថ្ងៃខួបកំណើតចុងក្រោយ) **ឬ**

ច. ក្រុមហ៊ុនបញ្ចប់គម្រោងមូលដ្ឋាន ស្របតាម ខ និងលក្ខខណ្ឌដែលមានចែងក្នុងនេះ **ឬ**

ឆ. មានស្ថានភាពផ្សេងទៀត ដែលកំណត់ដោយច្បាប់ស្តីពីការធានារ៉ាប់រងដែលមានស្រាប់ **ឬ**

ជ. ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការធ្វើការបញ្ចប់បណ្ណសន្យារ៉ាប់រង ឬមិនផ្តល់ជូនសំណង ក្នុងករណីម្ចាស់សន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះមិនបានផ្តល់ជូនព័ត៌មានពិតសំខាន់ៗសម្រាប់ការវិភាគកម្រិតហានិភ័យមុនការចេញបណ្ណសន្យារ៉ាប់រង ឬការផ្តល់ជូនផ្សេងទៀតនៃកញ្ចប់ផលិតផលនេះ។

*******************************